## គោលការណ៍របស់ធនាគារ

លោកអ្នកអាចដាក់លុយក្នុងធនាគារ

សៀវភៅស្តើងដែលណែនាំពីសេវាបំរើរបស់ធនាគារ និង Credit union ដូចជា គណនីសំរាប់ចាយ គណនីសន្សំ ការដាក់លុយដោយមានសំបុត្របញ្ជាក់ហើយ នឹងប័ណ្ណឥណទាន ( ហៅឲ្យខ្លីជាប័ណ្ណខ្ចីលុយ ) ។ នៅមានរៀបរាប់ពីការបើក គណនីនិងដោះស្រាយបញ្ហា ។

## មាតិការរឿង

- *ដាក់លុយក្នុងធនាគារ
- *ការត្រួតពិនិត្យលើ គណនីដែលទើបបើកថ្មី
- *គណនីសំរាប់ចាយ
- *ប្រើប័ណ្ណឥណពន្ធ ( ប័ណ្ណបើកលុយ )
- *គណនីសន្សំ
- *ដាក់លុយដោយមានសំបុត្របញ្ជាក់
- *ប្រអប់ទុកឥវ៉ាន់មានសុវត្ថិភាព
- *បើកគណនី
- *ទូទាត់សៀវភៅសែក
- *ដោះស្រាយបញ្ហា

## ទុកលុយក្នុងធនាគារ

ជាកន្លែងមានសុវត្ថិភាព និងងាយស្រួលក្នុងការទុកលុយ

ធនាគារ-មានធនាគារសំរាប់ពាណិជ្ជកម្ម សមាគមសន្សំនិងឲ្យខ្ចីលុយ ធនាគារសំរាប់សន្សំលុយនិង Credit union ជាក្រុមហ៊ុនដែលរក្សាលុយ របស់លោកអ្នក ហើយផ្តល់ការងាយស្រួលក្នុងការប្រើប្រាស់ផង ។ គណនីក្នុងធនាគារអាចជួយ

ឲ្យលោកអ្នកកត់ត្រាពីចំណាយផ្សេងៗ ។
ធនាគារជាក្រុមហ៊ុនរកចំណេញ-ប្រាក់កំរៃរបស់គេ គឺបានមកពីថ្លៃឈ្នួលផ្សេងៗ ហើយនឹងការឲ្យគេខ្ចីលុយ ។ លុយក្នុងធនាគារត្រូវបានទទួលការធានាពីសហព័ន្ធរដ្ឋាភិបាល ។ ការធានារ៉ាប់រង់ជាគោលអាស្រ័យទៅនឹងចំនួនលុយរបស់លោកអ្នក-មានចំនួនរហូតដល់ $250,000
ចំពោះមនុស្សម្នាក់ៗនៅក្នុងធនាគារតែ មួយ ។
លោកអ្នកអាចទទួលប្រាក់ធានាច្រើន ជាងនេះទៅទៀតបើសិនជាមានគណនីផ្សេងៗច្រើនទៀតនៅក្នុងធនាគារតែមួយ ដូចជាគណនីជាមួយមនុស្សម្នាក់ផ្សេងទៀត ឬក៏គណនីសន្សំសំរាប់ពេលចូលនិវត្តន៍ (IRA) ស្ថាប័នដែលបានទទួលការធានាត្រូវដាក់តាំងលិខិតជាផ្លូវការដែលបញ្ជាក់ថា បានធានាដោយ Federal Deposit Insurance Corporation (FDIC) ។
Credit union ជាស្ថាប័នគ្មានយកចំណេញ ដែលដាក់លុយហើយគ្រប់គ្រង់ដោយសាមាជិករបស់វា ។ Credit union បំរើមនុស្សជាក្រុមរួមក្នុងផល់ប្រយោជន៍ជាមួយគ្នា ដូចជារួមការងារជាមួយគ្នា រស់នៅជាមួយគ្នា ។ Credit union ផ្តល់គណនីសំរាប់ចាយ គណនីសន្សំហើយឲ្យខ្ចីប្រាក់ ដោយអត្រាការប្រាក់ល្អជាងធនាគារសំរាប់ពាណិជ្ជកម្ម ។
The National Credit Union Share Insurance Fund គ្រប់គ្រងដោយ National Credit Union Administration ជាភ្នាក់ងាររបស់សហព័ន្ធរដ្ឋាភិបាល បានធានារ៉ាប់រង់ប្រាក់ដែលដាក់ទៅក្នុងគណនីមួយៗរបស់ Credit Union មានចំនួនដល់ទៅ $ 250.000 ។
ដើម្បីរក Credit Union សុំទូរស័ព្ទទៅ Credit union National Association លេខ 800-358-5710 ឬរកក្នុង website (www.cuna.org) ។

## ការត្រួតពិនិត្យលើភ្ញៀវថ្មី

បើលោកអ្នកបានធនាគារបដិសេធ មិនឲ្យបើកគណនី នៅក្នុងធនាគាររបស់គេ គឺមកពីមានឈ្មោះរបស់លោកអ្នក នៅក្នុងមូលដ្ឋាន ទិដ្ឋន័យនៃប្រព័ន្ធ Chexsystems ដែលជាក្រុមហ៊ុនក្នុងស្រុកដ៏ធំមួយ សំរាប់ត្រួតត្រាមើលគណនី ។ សេវានៃការត្រួតពិនិត្យគណនី អាចជួយឲ្យធនាគារពិនិត្យ មើលអ្នកដែលសុំបើកគណនីថ្មីដែលធ្លាប់មានបញ្ហាក្នុងការប្រើប្រាស់លុយកាលពីមុន ។ បើលោកអ្នកចាយលើសពីចំនួនប្រាក់ដែលមាន នៅក្នុងគណនីសំរាប់ចាយ ហើយទុកចោលដោយមិនបានសងគេ នុះឈ្មោះរបស់លោកអ្នក នឹងមាននៅក្នុងមូលដ្ឋាន ទិដ្ឋន័យនៃប្រព័ន្ធ Chexsystems នោះ ។

តាមច្បាប់នៃសហព័ន្ធ Chexsystems ចាត់ទុកថាជាការិយាល័យនៃការផ្តល់ពត៌មាន ពីការខ្ចីលុយ ហើយត្រូវឲ្យស្រប់ជាមួយនឹង ពត៌មានត្រឹមត្រូវពីការខ្ចីលុយ The Fair Credit Reporting Act (FCRA) ដែលប្រតិបត្តិដោយ Federal Trade Commission (FTC) ។ របាយការណ៍របស់ឯកជនម្នាក់ៗត្រូវរក្សាទុកជាឯកសារក្នុងកំឡុង 5ឆ្នាំ លើកលែងតែធនាគារឬ Credit Union ដែលទុកឯកសារនោះដកចេញវិញមុនពេលកំណត់ ។ ការសំរេចពីលប់ឯកសារចោល ស្ថិតនៅលើធនាគារ ឬ Credit Union ដែលជាអ្នកផ្តល់ពត៌មានឲ្យគេ ។

លោកអ្នកមានសិទ្ធិនឹងបានទទួលលិខិតចម្លង នៃរបាយការណ៍ពី chex systems រៀងរាល់ឆ្នាំ ។ ដើម្បីឲ្យបានលិខិតចម្លងនេះសុំទូរស័ព្ទទៅលេខ 800-428-9623 ឬ www.consumerdebit.com ។ លិខិតចម្លងនេះត្រូវផ្ញើមកឲ្យលោកអ្នកដែរ បើធនាគារបដិសេធមិនឲ្យបើកគណនី ឬក៏លោកអ្នកជាជនរងគ្រោះពីការក្លែងបន្លំ ។

ឧទាហរណ៍ដូចជាមានគេលួចសែកហើយក្លែងបន្លំហត្ថលេខារបស់លោកអ្នក

ដើម្បីប្រើសែកនោះ ។
របាយការណ៍ពី Chexsystems មានអនុទ្ទេសសំរាប់ដោះស្រាយពីពត៌មានដែល មិនត្រឹមត្រូវ ។ ក្រុមហ៊ុននេះត្រូវតែស៊ើបអង្កេតពីការតវ៉ា របស់លោកអ្នកហើយ ត្រូវប្រាប់ពីលទ្ធផលមកលោកអ្នក ក្នុងរយៈពេល 30ថ្ងៃ ។
Scan (shared check Authorization Network) ហើយនិង Tele check ជាមូលដ្ឋានទិន្នន័យនៃការផ្ញើ check ត្រឡប់ទៅអ្នកសរសេរវិញ ។ បើហាងលក់ ទំនិញមួយណាមិនព្រមទទួលសែករបស់លោកអ្នក នោះលោក
លោកអ្នកត្រូវមានលេខប្រចាំខ្លួន (PIN) ដើម្បីប្រើប្រាស់ប័ណ្ណនេះ ។ ត្រូវអាន " ការប្រើប័ណ្ណឥណពន្ធ " ។ លោកអ្នកមានលទ្ធភាពនឹងប្រើប័ណ្ណ ATM ព្រម ទាំង ប្រើលេខប្រចាំខ្លួនដើម្បីទិញរបស់របរហើយនឹងបើកលុយចេញពីហាងលក់ ទំនិញផង ។

**ធនាគារ និង** credit union **អាចផ្តល់គណនីចំណាយជាច្រើនប្រភេទ ។**

- គណនីចំណាយដោយគ្មានគិតថ្លៃ - គ្មានការបង់ប្រចាំខែ និងគ្មានការ កំណត់ថាត្រូវទុកលុយប៉ុន្មានដែរក្នុងមួយខែៗ -នឹងផ្តល់ឲ្យលោកអ្នក បើសិនជាយល់ព្រមថានិងដាក់សែកទៅក្នុងគណនី Electronically ។ ការដាក់សែកផ្ទាល់នេះ ប្រកបដោយសុវត្ថិភាព ( សែកអាចជាបាត់ ឬត្រូវគេលួច ) ហើយងាយស្រួល( លោកអ្នកមិនចាំបាច់ទៅធនាគារ ឬម៉ាស៊ិន ATM ដើម្បីដាក់លុយចូល) បើលោកអ្នកព្រមព្រៀងថានឹងប្រើ ម៉ាស៊ិន ATM សំរាប់ដាក់លុយចូលនិង ដកចេញពីគណនី ដើម្បីកុំឲ្យខាត ពេលនឹងចូលទៅធនាគារនោះ លោកអ្នកក៏អាចបានគណនីនេះដែរ ។
- ការផ្ទេរលុយតាម electronic (ETAs)អាចធ្វើបាន បើលោកអ្នកបាន ទទួលកំរៃពីសហព័ន្ធដូចជា Social Security ឬ Supple-mental Security

Disability Income (SSDI) ។ ETA នឹងផ្តល់ឲ្យលោកអ្នកនូវប័ណ្ណមួយ ដែលអាចបើកលុយចំនួនបួនដងក្នុងមួយខែ ។ លុយអាចបើកពីធនាគារ របស់លោកអ្នក ឬពីម៉ាស៊ិន ATM របស់ credit union ឬ ប្រើសំរាប់ទិញឥវ៉ាន់ពីហាងលក់ទំនិញ ETA មិនផ្តល់សែកឲ្យទេ ។ សុំទូរស័ព្ទទៅលេខ 888-382-3311 ឬ online www.eta.org បើចង់រកធនាគារ ឬ credit union ដែលមាន ETA ។

*គណនីធម្មតា អាចមិនតំរូវឲ្យលោកអ្នកទុកលុយក្នុងកំរិតទាប - បានសេចក្តីថាលោកអ្នកមិនបាច់បង់ថ្លៃប្រចាំខែ បើលុយសល់ក្នុងគណនី មានកំរិតទាបពេក ។ រដ្ឋខ្លះតំរូវឲ្យធនាគារផ្តល់គណនីប្រភេទនេះសំរាប់ ជួយសំរួលភ្ញៀវដែលមានប្រាក់ខែតិច ។ គណនីនេះជូនកាលកំរិតចំនួន សែក។

*ប្រើប្រាស់លុយតាម Internet អាចឲ្យលោកអ្នកមើលលុយកាក់តាម កុំព្យូទ័រ ។ បើលោកអ្នកប្រើប្រាស់លុយតាម Internet (internet online Bank)លោកអ្នកនឹងដាក់លុយក្នុងគណនីដោយផ្ញើទៅធនាគារ ដាក់តាម ម៉ាស៊ិន ATM ឬដាក់ចូលគណនីដោយស្វ័យប្រវត្តិ ។លោកអ្នកត្រូវបើក លុយពីម៉ាស៊ិន ATM ក្នុងស្រុក ។ internet online bank ខ្លះសងថ្លៃដែល គេគិតពេលលោកអ្នកប្រើ ATM របស់ធនាគារផ្សេង ។ លើសពីនេះលោកអ្នកអាចនឹងបាត់បង់លុយទាំងអស់នៅក្នុងគណនី ហើយនឹងផ្នែកខ្លះនៃចំនួនប្រាក់ដែលគេអនុញ្ញាតិឲ្យខ្ចីពេលអស់ លុយបើសិនជាលោកអ្នកមិនបានរាយការណ៍ពីការផ្ទេរលុយ ឬការដក ប្រាក់ដោយគ្មានការអនុញ្ញាតិក្នុងរវាង 60ថ្ងៃបន្ទាប់ពីបានទទួលតុល្យ បញ្ជីពីធនាគារ ។

បើលោកអ្នកឲ្យប័ណ្ណនេះព្រមទាំងលេខសម្ងាត់ទៅអ្នកផ្សេង លោកអ្នកត្រូវទទួលខុសត្រូវពីការដកលុយ ទោះជាមិនបានអនុញ្ញាតិឲ្យគេប្រើក្តី ។ ទុកលេខសម្ងាត់ដោយប្រុងប្រយ័ត្ន-កុំសរសេរលើប័ណ្ណឲ្យទៅនរណាឲ្យសោះ ។

**គណនីសន្សំ ។**

គណនីសន្សំជាកន្លែងសុខសំរាប់សន្សំលុយ ហើយបានទទួលការប្រាក់ កាលណាលោកអ្នកបើកគណនីសន្សំ ធនាគារនឹងឲ្យកូនសៀវភៅដែលកត់ត្រាប្រាក់ដាក់ចូល និងប្រាក់បើក ។ ធនាគារខ្លះមិនឲ្យកូនសៀវភៅទេ គេនឹងផ្ញើតុល្យបញ្ជីទៅឲ្យរៀងរាល់ខែ ឬក្នុងបីខែម្តង ។ លោកអ្នកអាចសុំប័ណ្ណ ATM សំរាប់ដាក់ឬបើកលុយ ។ ( លោកអ្នកអាចប្រើក្រដាស់សំរាប់បើកលុយ ឬដាក់លុយពេលទៅធនាគារ ) អាស្រ័យទៅលើធនាគារ ហើយនិងប្រភេទនៃគណនីសន្សំ លោកអ្នកអាចត្រូវធនាគារកំរិតចំនួនបើកលុយពីម៉ាស៊ិន ATM ដោយមិនគិតថ្លៃក្នុងមួយខែៗ ។ លុយដែលដាក់ក្នុងធនាគារសន្សំ បានទទួលការប្រាក់ ។ ធនាគារភាគច្រើនមិនឲ្យការប្រាក់ច្រើនទេ គឺតែមួយភាគរយ ឬពីភាគរយប៉ុណ្ណោះ ។ ការប្រាក់គឺជាអត្រាភាគរយក្នុងមួយឆ្នាំ (APR) –បើទុកលុយក្នុងគណនី ក្នុងពេលមួយឆ្នាំ ។ សព្វថ្ងៃនេះធនាគារភាគច្រើនឲ្យការប្រាក់មួយភាគរយចំពោះគណនីសន្សំ ។ បើលោកអ្នកមានលុយ $1000 ក្នុងគណនីប្រាក់កំរៃគឺ$ 10 ។

ការប្រាក់មានពីរប្រភេទ តែឯងនិងលាយគ្នា ។ ការប្រាក់លាយគ្នាគឺល្អណាស់ព្រោះមិនត្រឹមតែបានការប្រាក់លើលុយ ដែលមាននោះទេ គឺបានបានការប្រាក់បន្ថែមពីលើការប្រាក់នោះទៀត ។ ការប្រាក់លាយគ្នាបាន

ទទួលលើសពីមួយឆ្នាំហៅថាការប្រាក់ទិដ្ឋផល Annual percents yield (APY) ។

## ការដាក់លុយដោយមានសំបុត្របញ្ជាក់

ការដាក់លុយដោយមានសំបុត្របញ្ជាក់ ឬក៏CD អាចបានការប្រាក់ដែលមានការមិនគិតថ្លៃ ពេលដែលលោកអ្នក បង់ថ្លៃចំណាយនោះទេ ។ ដើម្បីការពារលុយរបស់លោកអ្នកឲ្យគង់វង់ គណនីទាំងអស់ត្រូវតែបានធានាដោយ FDIC ។

ចំពោះគណនីរបស់មនុស្សចាស់ ឬនិស្សិតគ្មានការកំរិតពីចំនួនដែលត្រូវទុកប្រាក់ក្នុងគណនីនោះ ។ អាចជាមានការកំរិតពីចំនួនសែកដែលត្រូវសរសេរហើយ បើប្រើលើសចំនួនដែលអនុញ្ញាតិនោះគេនឹងគិតថ្លៃ ។

## ប្រើប្រាស់ប័ណ្ណបើកលុយ

បើធនាគារផ្តល់ប័ណ្ណបើកលុយពីម៉ាស៊ិន ATM ដោយមានពាក្យថា Master Card ឬ Visa នៅលើប័ណ្ណនោះ គឺលោកអ្នកមានប័ណ្ណបើកលុយហើយ ។ ប័ណ្ណនេះ ភ្ជាប់ផ្ទាល់ទៅនឹងគណនីរបស់លោកអ្នក ។ កាលណាលោកអ្នកប្រើប័ណ្ណនេះលុយ នឹងដកចេញពីគណនីភ្លាម់ពេលទិញឥវ៉ាន់ ។ ប័ណ្ណនេះអាចប្រើបានដូចប័ណ្ណ Master Card ឬ Visa ដែរហើយអាចប្រើក្រៅប្រទេសបាន ។

## ប័ណ្ណបើកលុយអាចប្រើបានពីរយ៉ាង

*ត្រូវប្រើលេខសម្ងាត់ (PIN) ពេលដកលុយពីម៉ាស៊ិន ATM ឬទិញឥវ៉ាន់

*អាចផ្ញើប័ណ្ណនេះនៅតាមហាង ឬភោជនីយដ្ឋានដែលទទួលប័ណ្ណខ្ចីលុយ Credit card ដោយមិនបាច់ប្រើលេខសម្ងាត់ ។ លោកអ្នកគ្រាន់តែចុះហត្ថលេខាប៉ុណ្ណោះ ។

## ត្រូវប្រុងប្រយ័ត្នក្នុងការប្រើប័ណ្ណបើកលុយ

ត្រូវថែរក្សាប័ណ្ណបើកលុយ ។ ត្រូវប្រាប់ធនាគារភ្លាមមួយរំពេច កាលបើបាត់ប័ណ្ណនេះឬក៏ត្រូវគេលួច ដើម្បីជៀសវាងពីការប្រើប្រាស់ ដោយគ្មាន ការអនុញ្ញាតិ ។ បើបាត់ប័ណ្ណនេះ វាជាការស្រួលចំពោះអ្នកដែលរើសបានព្រោះថាលេខសម្ងាត់មិនត្រូវបានប្រើរាល់ពេលនោះឡើយ ។លោកអ្នកត្រូវទទួលខុសត្រូវកាលបើមាននរណាប្រើប័ណ្ណនេះទោះគ្មានការអនុញ្ញតិ ឬទោះជាចំនួនតិចក៏ដោយ ។ វាអាចជាត្រូវប្រើពេលយូរបន្និច ឬប្រើការប្រឹងប្រែងដើម្បីអាច បានទទួលប្រាក់សំណងពីធនាគារវិញ ។

ត្រូវរាយការណ៍ទៅធនាគារជាបន្ទាន់ ។ លោកអ្នកគ្មានត្រូវខាតបង់អ្វីទេ បើបានរាយការណ៍ក្នុងរយៈពេលពីថ្ងៃ ។ តែត្រូវបង់ $50កាលបើរាយការណ៍បន្ទាប់ពីមិនបង់ប្រើម៉ាស៊ិន ATM ទេ ។ ត្រូវសួរពីសំនួរសំខាន់ៗ ដូចតទៅ

- តើត្រូវមានលុយយ៉ាងតិចបំផុតប៉ុន្មានដែរ ដើម្បីគណនី ។
- តើអាចបានការប្រាក់ប៉ុន្មានដែរ ។
- តើមានការគិតថ្លៃក្នុងមួយខែៗប៉ុន្មានដែរ ។
- តើត្រូវធ្វើយ៉ាងណា បើលុយនៅក្នុងគណនីមានចំនួនតិច ជាងចំនួនដែលគេកំរិតឲ្យមាននោះ ។
- តើអាចសរសេរសែក ប៉ុន្មានដែរក្នុងមួយខែៗ ។
- តើត្រូវបង់លុយប៉ុន្មាន បើប្រើម៉ាស៊ិន ATM នោះ ?ចុះបើប្រើម៉ាស៊ិន ATM របស់ធនាគារឯទៀតនោះ ។

លោកអ្នកអាចទិញសែកផ្ទាល់ខ្លួនពីធនាគារ ( ធនាគារខ្លះគិតថ្លៃ $ 25ក្នុងមួយប្រអប់ដែលមានសែកចំនួន 250 សន្លឹក ) ឬទិញពីសេវាបោះពុម្ពសែកដែលគិតតម្លៃថោក ។ មានប្រភពពីរក្នុងការទិញសែកនេះ

* ទិញតាមការ order ដោយទូរស័ទ្ទទៅលេខ 800-733-4443

www.citm.com

* ទិញតាមសៀវភៅ catalog លេខ 800-848-2848

www.currentcatalog.com

## ធ្វើការទូទាត់សៀវភៅសែក

ធនាគារនឹងផ្ញើតុល្យបញ្ជីទៅលោកអ្នក ។ ត្រូវពិនិត្យតុល្យបញ្ជីយ៉ាងប្រញាប់ ដើម្បីត្រួតពិនិត្យមើថា តើការដាក់លុយ-ដកលុយ-ឥណពន្ធហើយនិងសែកនោះប្រាកដជាត្រឹមត្រូវ ។

ត្រូវកត់ត្រាគ្រប់ការដាក់លុយ-ដកលុយ-ឥណព័ន្ធ និងសែកនៅក្នុងសៀវភៅសំរាប់កត់ត្រា ។ បន្ទាប់ពីទទួលតុល្យបញ្ជីប្រចាំខែ ត្រូវធ្វើការទូទាត់គណនីតាមការណែនាំក្នុងបញ្ជីនោះ ។

## ល្បិចដើម្បីឲ្យធនាគារបញ្ចុះថ្លៃ

* ត្រូវសាកសួរថាតើអាច ប្តូកបញ្ចូលប្រាក់ពី គណនីសំរាប់ចាយ ទៅនឹងធនាគារសន្សំបានទេ ដើម្បីឲ្យស្របទៅនឹងតំរូវការនៃធនាគារហើយជៀសវាងការបង់លុយផង ។

ធានាក្នុងពេលកំណត់ ដូចជារយៈពេលមួយឆ្នាំ ។ លោកអ្នកអាចជ្រើសរើសយករយៈពេលនៃការទុកលុយ រាប់ពីចំនួនខែទៅចំនួនឆ្នាំ ។ ទុកក្នុងរយៈ ពេលរឹតតែវែងបានការប្រាក់ក៏កាន់តែច្រើន ។ បើលោកអ្នកដាក់លុយមុនកាលកំណត់ លោកអ្នកនឹងខាតការប្រាក់ក៏កាន់តែច្រើន ។ ធនាគារខ្លះធ្វើការពិន័យ ចំពោះការបើកលុយមុន កាលកំណត់ដែល គេនឹងដកយកពីលុយដែលដាក់នោះ ។

## ប្រអប់ទុកឥវ៉ាន់មានសុវត្ថិភាព

ប្រអប់ទុកឥវ៉ាន់មានសុវត្ថិភាព គឺជាកន្លែងល្អបំផុត សំរាប់ទុកក្រដាស់ស្នាម ឬវត្ថុផ្សេងៗឲ្យផុតពីភាពអាសន្នដូចជាភ្លើងឆេះ ទឹកជំនន់ ឬចោរលួច ។ ព្រោះដោយហេតុថា ទាល់តែម្ចាស់នៃប្រអប់នោះ ទើបអាចបើកប្រអប់បាននេះ គឺជាភាពផ្ទាល់ខ្លួន ។ ក្រុមហ៊ុនធានារ៉ាប់រង់ខ្លះ គិតតម្លៃថោកក្នុងការធានាវត្ថុមានតម្លៃដែលទុកក្នុងប្រអប់នេះ ជាជាងទុកក្នុងផ្ទះ ។ កុំទុកសំពៅដើមនៃបណ្ដាំមរតក ឬសំពៅដើមនៃការធានាជីវិតក្នុងប្រអប់នោះ ព្រោះគេអាចបិទផ្សារជិតបន្ទាប់ពីលោកអ្នកធ្វើមរណកាល ហើយកូនចៅរបស់លោកអ្នក ត្រូវតែមានការអនុញ្ញាតិពីតុលាការទើបអាចបើកបាន ។

## បើកគណនី

លោកអ្នកអាចបើកគណនីនៅធនាគារ ឬការិយាល័យរបស់ credit union ។ ត្រូវយកប័ណ្ណសំគាល់ខ្លួនដែលបង្ហាញពីរូបថត និងហត្ថលេខាព្រមទាំងលេខសំគាល់ខ្លួនទៅផង ។ បើលោកអ្នកគ្មានប័ណ្ណបើកបរ ប័ណ្ណសំគាល់ខ្លួន ឬលិខិតឆ្លងដែនត្រូវទូរស័ព្ទទៅសាកសួរជាមុនថា ត្រូវយកអ្វីទៅជាមួយខ្លះ ។ ត្រូវយកលុយ ឬសែកទៅដាក់ដើម្បីបើកគណនី ។ ត្រូវសាកសួរជាមុនថាគេតំរូវឲ្យដាក់លុយប៉ុន្មានដែរ ។

ដើម្បីជាចំនួយក្នុងការរកធនាគារ ឬ credit union ដែលល្អត្រឹមត្រូវ ត្រូវទូរស័ព្ទសាកសួរជាមុន ។

បើលោកអ្នកគិតថាអាច បើកគណនីបានត្រូវសាកសួរ ពីគណនី life line ឬគណនី ETA ។ ប្រាប់អ្នកតំណាងរបស់ធនាគារ ពីសេចក្ដីត្រូវការរបស់លោកអ្នក ។ ប្រាប់គេថាលោកអ្នកសរសេរសែក តែបន្តិចបន្តួចប៉ុណ្ណោះក្នុងរវាងមួយខែៗហើយថា

⁎ប្រើម៉ាស៊ិន ATM របស់ធនាគារដែលមិនគិតថ្លៃ ក្នុងការបើកលុយ ឬក៏ពី

ម៉ាស៊ិន ATM របស់ធនាគារណាដែលមិនគិតលុយ ពីអ្នកដែលមិនមែនជាភ្ញៀវរបស់គេ ។ បើកលុយម្តងៗឲ្យច្រើន ដើម្បីជៀសវាងការបង់លុយទៅលើលុយបើកបន្តិចៗជាច្រើនដង ។

*ដាក់ប្រាក់ខែ ឬប្រាក់កំរៃពីរដ្ឋាភិបាលផ្ទាល់ទៅក្នុងគណនីដោយប្រើប្រព័ន្ធអេឡេកត្រូនីក ។ ដាក់លុយផ្ទាល់គឺឆាប់រហ័ស មានសុវត្ថិភាពងាយស្រួលហើយអាចធ្វើឲ្យលោកអ្នកបានគណនីដោយមិនគិតថ្លៃផង ។

*ទិញសៀវភៅសែកតាមការ order ជាជាងតាមរយៈធនាគារ

*សុំឲ្យធនាគារធ្វើការសងមកវិញ ចំពោះការបង់ថ្លៃយឺតពេល ឬសែកគ្មានលុយ

*សេវាមួយទៀតឈ្មោះថា ការពារពេលគ្មានលុយក្នុងគណនីជួយលោកអ្នកពេលសរសេរសែកគ្មានលុយ ។ ការគិតថ្លៃចំពោះការផ្ទេរលុយ ឬការប្រាក់ថោកជាង ការគិតថ្លៃដែលសរសេរសែកគ្មានលុយ ។

## ការដោះស្រាយបញ្ហា

ដាក់លុយច្រឡំ មិនឃើញថាបានសងគេ ដកលុយពីរដង-ភាពខុសរបៀបនេះមិនកើតរាល់ថ្ងៃទេ ។ ប៉ុន្តែបើកើតត្រូវតវ៉ាជាបន្ទាន់ ។

ច្បាប់ប្រហែលជាកំរិតចំនួនតវ៉ា ។ បើលោកអ្នកចង់តវ៉ាត្រូវផ្តើមពីទូរស័ព្ទទៅ customer service representative

ឬទៅធនាគារ ។

ត្រូវសួរឈ្មោះអ្នកដែលលោកអ្នកជួបនោះហើយកត់ទុក។ ក្នុងពេលនិយាយគ្នានេះត្រូវប្រាប់គេថា លោកអ្នកចង់ធ្វើយ៉ាងណា ហើយសុំឲ្យគេកែតំរូវរឿងនេះតាមពេលកំណត់ ។ កុំឆេវឆាវ ។ តម្លើងសំឡេង ឬកំរាមកំហែងមិនបានទទួលសហការពីបុគ្គលិករបស់ធនាគារឡើយ ។

ធ្វើការសង្ខេបពីការសន្ទនាជាមួយបុគ្គលិកនេះ នៅក្នុងលិខិតហើយផ្ញើទៅឲ្យធនាគារ ។ ថតចម្លងឯកសារទាំងអស់ភ្ជាប់ជាមួយពាក្យតវ៉ានោះ ( សុំកុំផ្ញើច្បាប់ដើមឲ្យសោះ ) ។ លិខិតរបស់លោកអ្នក នឹងបញ្ជាក់ពីការតវ៉ាយ៉ាងឆាប់រហ័ស ។ បើលោកអ្នកមិនពេញចិត្ត និងការឆ្លើយតបរបស់ធនាគារ នោះអាចតវ៉ាទៅនិយតកររបស់ធនាគារ (bank regulator) ។

∗ធនាគារដែលមានឈ្មោះ "National " ឬ " N.A" ពីក្រោយឈ្មោះត្រូវបានត្រួតត្រាដោយ Comptroller of the currency លេខ 800-613-6743 ( www.helpwithmybank.gov)

∗ធនាគារសន្សំនិងខ្ចីលុយរបស់សហព័ន្ធ ហើយនឹងធនាគារសន្សំជាឯកជនត្រូវបានត្រួតត្រាដោយ Office of thrift supervision លេខ 800-842-6929 (www.ots.treas.gov) ។

∗state-chartered bank ត្រូវបានត្រួតត្រាដោយ state-chartered banking authorities ដើម្បីរកភ្នាក់ងារនៅក្នុងរដ្ឋរបស់លោកអ្នក ត្រូវរកផ្នែកខាងរដ្ឋាភិបាល ក្នុងទំព័រសនៃសៀវភៅអាសយដ្ឋាន ឬក្នុង internet ((http://consumeraction.gov/banking.shtml) ។

∗Federally chartered credit union ត្រូវបានត្រួតត្រាដោយ National credit union Administration. លេខ 703-518-6330 www.ncua.gov) ។ បើលោកអ្នកគិតថាធនាគាររបស់លោកអ្នកគ្មាននៅក្នុង ស្ថាប័នប្រភេទទាំងនេះទេត្រូវទាក់ទងទៅ FDIC លេខ 800-934-3342 ដែលត្រួតត្រារួមគ្នាពីធនាគារមួយណាដែលធនានារ៉ាប់រងដោយ FDIC ។

ចប់5